00648652



ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 01 / 03 / 2011
ម៉ោង (Time/Heure): 13:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អនុស្សរណៈ - អង្គជំនុំជម្រះសាលាដំបូង** **សាធារណៈ / Public**

**ជូនចំពោះ :** **គ្រប់ភាគីទាំងអស់នៃសំណុំរឿង ០០២** កាលបរិច្ឆេទ: ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០១១

**ចម្លងជូន :** លោកប្រធាន និងលោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង

**ពី :** **Susan LAMB** មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ :** **ការកំណត់ចំនួនទំព័រសម្រាប់ការដាក់អញ្ញត្រកម្ម**

យោងទៅលើអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០១១ ដែលបានទទួលស្គាល់ពីឆន្ទៈរបស់ក្រុមមេធាវីការពារឱ្យលោក នួន ជា ក្នុងការបង្រួមនូវអញ្ញត្រកម្មរបស់ខ្លួនទៅជាឯកសាររួមតែមួយ ដែលមិនលើសពីចំនួន ១៥ ទំព័រ។ អង្គជំនុំជម្រះក៏បានយល់ព្រមឱ្យមេធាវីការពារឱ្យ លោក អៀង សារី បន្ថែមនូវចំនួនទំព័ររហូតដល់ ២៥ ទំព័រដើម្បីដាក់អញ្ញត្រកម្មរួមរបស់ពួកគេ។

គោលបំណងសំខាន់របស់សេចក្ដីណែនាំនេះ គឺដើម្បីដោះស្រាយនូវលទ្ធភាពដែលមានកំរិតក្នុងការបកប្រែឯកសារដោយអង្គភាពបកប្រែភាសា ក្នុងការបកប្រែឯកសារដែលមានសារៈសំខាន់ក្នុងចំនួនទំព័រដ៏ច្រើនសន្ធឹកសន្ធាប់ជាភាសាខ្មែរក្នុងរយៈពេលមួយសមស្រប។ ដូច្នេះហើយវាមិនពាក់ព័ន្ធដល់ដំណើរការនៃការបកប្រែឯកសាររបស់អង្គភាពបកប្រែភាសាទៅលើឯកសារដែលបានដាក់ពីមុនដោយក្រុមមេធាវីការពារឱ្យលោក នួន ជា នោះទេ។

ក្រោយពីបានពិភាក្សាជាមួយក្រុមមេធាវីការពារឱ្យជនជាប់ចោទដែលមិនទាន់បានដាក់អញ្ញត្រកម្មរបស់ខ្លួន ហេតុដូច្នេះ អង្គជំនុំជម្រះនឹងទទួលយកការដាក់អញ្ញត្រកម្មពីមេធាវីការពារឱ្យលោក នួន ជា ដែលមិនឱ្យលើសពីចំនួន ៣៥ ទំព័រ និងមិនឱ្យហួសពីថ្ងៃសុក្រ ទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១ និងពីក្រុមមេធាវីការពារឱ្យលោក អៀង សារី ដែលមិនឱ្យហួសពីថ្ងៃច័ន្ទ ទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១១ (ជាភាសាអង់គ្លេសជាមុន ហើយផ្ដល់ឯកសារបកប្រែភាសាខ្មែរ ក្នុងរយៈពេលសមស្របណាមួយ)។

ECCC, National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia
Tel: +(855) 023 219 814 Fx: +(855) 023 219 841 Web: www.eccc.gov.kh

ក្រោយពីបានទទួលនូវសំណើសុំរបស់មេធាវីការពារឱ្យលោក ខៀវ សំផន ក្នុងការដាក់អញ្ញត្រកម្ម ដែលលើសពីចំនួនទំព័រកំណត់ ១៥ ទំព័រ ហើយដែលមិនមានការបន្ថែមចំនួនទំព័រកំណត់ដែលត្រូវផ្តល់ឱ្យចំពោះក្រុមនេះទេ។ ជាថ្មីម្តងទៀត អង្គជំនុំជម្រះសូមអរគុណ ចំពោះក្រុមមេធាវីការពារឱ្យអ្នកស្រី អៀង ធីរិទ្ធ ដែលបានដាក់អញ្ញត្រកម្មរបស់ខ្លួនជាលើកដំបូង ស្របទៅតាមចំនួនទំព័រដែលបានកំណត់ក្នុងការដាក់ឯកសារគឺចំនួន ១៥ ទំព័រ។

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE